# មេរៀនទី ១៤៧៖ យ៉ូណាសតវ៉ាពីក្ដីមេត្តារបស់ព្រះចំពោះទីក្រុងនីនីវេ

## យ៉ូណាស ៣៖១០-៤៖១១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ePh2drJsW1w

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/pH5e7dDUdPw

**គោលបំណង៖ ព្រះទ្រង់ស្រលាញ់មនុស្សគ្រប់គ្នា សូម្បីតែអ្នកដែលមិនស្គាល់ទ្រង់ក៏ដោយ។**

**ខគម្ពីរចងចាំ៖ យ៉ូហាន ៣៖១៧** "ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ។"

**ចំរៀង** ( *យូធូបលីង* )៖

១. តើអ្នកណាជាម្ចាស់នៃខ្ញុំ https://youtu.be/e4gCJBfWNTs
២. ក្តីសប្បុរសទ្រង់ https://youtu.be/3Dvd4xrD_TI
៣. ទ្រង់មិនដែលខាន https://youtu.be/uVqBqBENPi4

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ញុំាផ្លែឈើប្រណាំងគ្នា»



សម្ភារៈដែលត្រូវការ៖ ផ្លែ ប៊ិគក់ និងខ្សែ
១. ចែកកុមារជា២ក្រុម ហើយឲ្យគេជ្រើសរើសតំណាងក្រុមម្នាក់។
២. តំនាងក្រុមទាំង២ត្រូវឡើងមកខាងមុខ ហើយព្យាយាមញុំាផ្លែប៊ិគក់ដែលបានចងព្យួរនោះ
៣. គ្រូត្រូវទុកពេលឲ្យកុមារ២ នាទីក្នុងការញុំា កុមារដែលអាចញុំាបានច្រើនជាងក្រុមនោះជាអ្នកឈ្នះ។
៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា បើទោះបីជាយើងមានការពិបាកក្នុងការញុំាប៊ិគក់យ៉ាងណាក៏ដោយតែយើងនៅតែអាចធ្វើវាបាន។ ក៏ដូចគ្នានេះដែលប្រហែលជាយើងគិតថាយើងពិបាកក្នុងការស្រលាញ់មនុស្សដែលមិនស្រលាញ់ព្រះ ប៉ុន្តែព្រះគឺស្រលាញ់មនុស្សគ្រប់គ្នា បើទោះបីជាពួកគេ មិនបានស្គាល់ព្រះក៏ដោយ។

### ៤. ការណែនាំមេរៀន

តើអ្នកគិតថាតម្លៃដ៏អស្ចារ្យបំផុតសម្រាប់ព្រះគឺជាអ្វី? មនុស្សគឺជាតម្លៃដ៏អស្ចារ្យបំផុតសម្រាប់ព្រះ - គឺមនុស្សគ្រប់គ្នាទាំងអស់ មិនថាពួកគេមិនបានស្គាល់ទ្រង់ ឬពួកគេស្រលាញ់ព្រះអង្គក៏ដោយ។ មិនថាកូនក្មេង លោកយាយលោកតា និងមនុស្សមកពីគ្រប់ជាត់សាសន៍គឺ ពួកគេទាំងអស់គ្នាបានទទួលនូវសេចក្ដីស្រលាញ់ដ៏អស្ចារ្យរបស់ព្រះអង្គ។ ប៉ុន្តែយ៉ូណាសដែលជាហោរាមិនបានស្រឡាញ់មនុស្សទាំងអស់នោះទេ។ ថ្ងៃនេះ យើងនឹងរៀនជាមួយគ្នាពីប្រតិកម្មរបស់យ៉ូណាសនៅពេលដែលព្រះបានសង្គ្រោះសត្រូវរបស់គាត់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

កាលពីមេរៀនមុនយើងបានរៀនអំពីរបៀបដែលយ៉ូណាសមិនស្ដាប់បង្គាប់ព្រះនិងព្យាយាមរត់គេច ដូច្នេះគាត់មិនចាំបាច់ទៅផ្សព្វផ្សាយពីដំណឹងល្អរបស់ព្រះទៅកាន់មនុស្សម្នានៅឯនីនីវេនោះទេ ដោយព្រោះពួកគេ គឺជាសត្រូវរបស់អ៊ីស្រាអែល។ ប៉ុន្តែព្រះបានប្រើត្រីធំមួយដើម្បីលេបលោកយ៉ូណាស ដើម្បីផ្លាស់ប្ដូរគំនិតរបស់គាត់ និងជួយគាត់ឲ្យស្ដាប់បង្គាប់ព្រះ។

នៅពេលដែលយ៉ូណាសស្ដាប់បង្គាប់ព្រះ និងប្រាប់មនុស្សថា ក្នុងរយៈពេល៤០ថ្ងៃ ព្រះនឹងបំផ្លាញទីក្រុងរបស់ពួកគេ ដោយសារតែអំពើទុច្ចរិតរបស់ពួកគេ ពួកគេក៏បានប្រែចិត្ត និងទុកចិត្តព្រះក្នុងការសង្គ្រោះពួកគេ។ ព្រះគម្ពីរបានប្រាប់យើងថាគឺមានមនុស្សច្រើនជាង ១២០ ០០០នាក់ នៅនីនីវេបានប្រែចិត្ត។ ព្រះសប្បាយព្រះទ័យនៅពេលដែលពួកគេមានការប្រែចិត្ត ពីព្រោះព្រះអង្គគឺស្រលាញ់ប្រជាជនទាំងអស់ នៅឯនីនីវេតាំងតែពីពួកគេមិនទាន់ស្គាល់ព្រះមកម្លេះ។ ព្រះគឺស្រលាញ់មនុស្សគ្រប់ៗគ្នា ហើយព្រះអង្គគឺ ចង់សង្គ្រោះមនុស្សទាំងអស់គ្នាផងដែរ។

ប៉ុន្តែយ៉ូណាសមិនសប្បាយចិត្តនោះទេ។ យ៉ូណាសគឺចង់ឃើញព្រះដាក់ទោសទីក្រុងនីនីវេ។ គាត់បានសម្រេចចិត្តទៅកន្លែងមួយដែលអាចមើលឃើញទីក្រុងទាំងមូល ដើម្បីមើលព្រះកម្ទេចទីក្រុងនោះ។ វាគឺពិតជាក្ដៅខ្លាំងណាស់នៅឯវាលខ្សាច់ ដូច្នេះព្រះបានបង្កើតវល្លិ៍ដើម្បីជួយបាំងយ៉ូណាសពី កម្ដៅថ្ងៃដ៏ក្ដៅនោះ។ ម្លប់ និងខ្យល់បានធ្វើឲ្យយ៉ូណាសមានអារម្មណ៍ល្អណាស់ ហើយគាត់ក៏គេងលក់ទៅ។ នៅព្រឹកព្រលឹមបន្ទាប់ ព្រះបានដាក់សត្វដង្កូវឲ្យមកស៊ីដើមវល្លិ៍នោះហើយវាក៏ងាប់ទៅ។ នៅពេលដែលយ៉ូណាសបានភ្ញាក់ពីគេង ព្រះអាទិត្យគឺពិតជាក្ដៅខ្លាំងមែនទែន ប៉ុន្តែគឺមិនមានម្លប់ដើមវល្លិ៍ ជួយឲ្យគាត់ត្រជាក់នោះទេ! យ៉ូណាសក៏ចាប់ផ្ដើមខឹងកាន់តែខ្លាំងឡើង!

ព្រះមានបន្ទូលទៅយ៉ូណាស “ឯងបានអាល័យ ចំពោះដើមវល្លិ៍ ដែលឯងមិនបានដាំ ឬធ្វើឲ្យដុះឡើងទេជាដើមដែលដុះឡើងក្នុង១យប់ ហើយបានវិនាសទៅ ក្នុង១យប់ដូចគ្នានោះ។ ប៉ុន្តែឯងមិនបានខ្វល់ពីទីក្រុងដ៏ធំមួយដែលពោរពេញទៅដោយមនុស្សដែលចង់ស្គាល់អញនោះទេ! តើឯងយល់ដែរឬទេយ៉ូណាសថាយើងស្រលាញ់អ្នកទាំងនោះ។ ដូច្នេះ តើមិនគួរឲ្យអញអាល័យ ចំពោះក្រុងនីនីវេ ជាទីក្រុងយ៉ាងធំនេះទេឬអី។”

តើអ្នកធ្លាប់គិតថាចង់ដាក់ទោសចំពោះអ្នកដែលបានធ្វើអ្វីមួយខុសដែរឬទេ? តើអ្នកធ្លាប់ខឹងដោយ ព្រោះគេមិនត្រូវបានដាក់ទោស ប៉ុន្តែបែរជាទទួលបាននូវការអត់ទោសទៅវិញ? នោះហើយគឺជាអារម្មណ៍ដែលយ៉ូណាសមាន។ ប៉ុន្តែព្រះបានយកចិត្តទុកដាក់ចំពោះប្រជាជននីនីវេវង្វេងឆ្ងាយ ដែលយ៉ូណាសមិនអាចយល់បាន។

ព្រះស្រលាញ់យើងបើទោះបីជាយើងមិនបានធ្វើនូវរឿងត្រឹមត្រូវក៏ដោយ។ ព្រះគឺស្រលាញ់មនុស្សគ្រប់គ្នារាប់ទាំងអ្នកដែលមិនមានទំនាក់ទំនងជាមួយទ្រង់ក៏ដោយ។ ព្រះស្រលាញ់មនុស្សគ្រប់គ្នាបើទោះបីជាគេមិនដឹងពីផែនការរបស់ទ្រង់ក៏ដោយ។ ព្រះស្រលាញ់ឧក្រិដ្ឋជននិងសមាជិកក្រុមជំនុំផងដែរ។ ហើយព្រះចង់ បំពេញសេចក្ដីស្រលាញ់របស់ទ្រង់ចំពោះយើង ដូច្នេះយើងអាចបង្ហូរវាទៅកាន់អ្នកដែលនៅជុំវិញខ្លួនយើងផងដែរ។ សូមឲ្យយើងស្រលាញ់ដល់អ្នកដែលមិនស្គាល់ព្រះអង្គ ពីព្រោះព្រះអង្គក៏ស្រលាញ់ពួកគេដែរ!

### ៦. សំនួរពិភាក្សា

១. តើអ្វីដែលធ្វើឲ្យយ៉ូណាសខឹង ?
*(ព្រះបានអត់ទោសឲ្យទីក្រុងនីនីវេ ជំនួសឲ្យការដាក់ទោសលើពួកគេ)*
២. តើព្រះបានប្រទានអ្វីដល់យ៉ូណាសនៅពេលដែលគាត់អង្គុយនៅក្រោមកម្ដៅថ្ងៃក៏ក្ដៅ ដើម្បីមើលពីការដាក់ទោសរបស់ព្រះចំពោះទីក្រុងនីនីវេនោះ ? *(គឺដើមវល្លិ៍ដើម្បីបាំងគាត់ពីកម្ដៅថ្ងៃ)*
៣. តើយ៉ូណាសមានប្រតិកម្មយ៉ាងណានៅពេលដែលដើមវល្លិ៍នោះងាប់ ?*(គាត់ខឹង)*
៤. តើព្រះបានប្រើដើមវល្លិ៍នោះ ដើម្បពន្យល់ពីសេចក្ដីស្រលាញ់របស់ព្រះអង្គចំពោះមនុស្ស ដែលរស់នៅទីក្រុងនីនីវេដោយរបៀបណា ? *(យ៉ូណាសបានអាល័យ ចំពោះដើមវល្លិ៍ ជាដើមដែលដុះឡើងក្នុង១យប់ ហើយបានវិនាសទៅ ក្នុង១យប់ដូចគ្នានោះ ចុះតើទ្រង់ខ្វល់ខ្វាយចំពោះមនុស្សដែលរស់នៅទីក្រុងនីនីវេប៉ុណ្ណា)*

### ៧. ល្បែងកំសាន្ត « បំបែកប៉េងប៉ោង »

សម្ភារៈដែលត្រូវការ៖ ខ្សែសំរាប់ចងប៉េងប៉ោង,ខ្សែ (សម្រាប់ចងកជើងកុមារ)
១. គ្រូឲ្យប៉េងប៉ោង និងខ្សែទៅកុមារនីមួយៗហើយឲ្យពួក គេយកខ្សែចងប៉េងប៉ោងកជើងពួកគេគ្រប់ៗគ្នា។
២.កុមារទាំងអស់ត្រូវប្រើប្រអប់ជើងរបស់ពួកគេក្នុង ការបំបែកប៉េងប៉ោងរបស់ក្រុមផ្សេងទៀត ប៉ុន្តែនៅក្នុង



ពេលជាមួយគ្នានោះដែរពួកគេត្រូវព្យាយាមការពារប៉េងប៉ោងរបស់ខ្លួនមិនត្រូវឲ្យគេបំបែកបានផងដែរ។
៣.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា មនុស្សមួយចំនួនចង់ឃើញសត្រូវរបស់យើងបរាជ័យ ហើយត្រូវ បានបំផ្លាញ។ ប៉ុន្តែព្រះមិនចង់ឃើញនរណាម្នាក់បរាជ័យ និងត្រូវបានបំផ្លាញនោះទេ។ ជំនួសឲ្យការ ទាំងអស់នោះព្រះបានស្រលាញ់ និងសង្គ្រោះពួកគេ គឺដូចជាការដែលទ្រង់បានសង្គ្រោះទីក្រុងនីនីវេអីចឹង។

### ៨. ខគម្ពីរចងចាំ

**យ៉ូហាន ៣៖១៧** “ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ។”

### ៩. ហត្ថកម្ម

សូមផាត់ពណ៌រូបភាព **“យ៉ូណាស និងដើមវល្លិ៍”**

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
តើពេលណាដែលយើងគួរតែមេត្តាចំពោះអ្នកដទៃ យើងគួរតែចែករំលែកសេចក្ដីស្រលាញ់ ដែលព្រះយេស៊ូវបានបង្ហាញពួកយើង។ តើសេចក្ដីមេត្តាសម្រាប់អ្នកគឺជាអ្វី? ប្រហែលជាវាមានន័យថា ការអត់ទោសឲ្យសត្រូវរបស់អ្នក ឬក៏ផ្ដល់ឲ្យដល់អ្នកដែលត្រូវការ។ សេចក្ដីមេត្តាគឺកើតឡើងតាមទម្រង់ជាច្រើន។ ហើយវាគឺជាផ្លូវដ៏ល្អ ក្នុងការចែកចាយពីសេចក្ដីស្រលាញ់របស់ព្រះយេស៊ូវទៅកាន់អ្នកដទៃ។ តើអ្នកអាចចែករំលែកសេចក្ដីស្រលាញ់តាមរយៈសេចក្ដីមេត្តាបានយ៉ាងដូចម្ដេច? សូមទូលសុំទៅកាន់ព្រះក្នុងការជួយអ្នកឲ្យដឹងពីរបៀបដែលអ្នកអាចមានចិត្តមេត្តាបាន។ ប្រាកដណាស់ទ្រង់នឹងបង្ហាញវាដល់អ្នក។

# យ៉ូណាស និងដើមវល្លិ៍



សូមសរសេរខគម្ពីរចងចាំ៖______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________